# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខៈ 5741...កសក

## សេចក្តីប្រកាស

## ស្តីពី

## ការផ្អាកសកម្មភាពអាជីវកម្មព្រៃគុបសំរាប់ក្រុមហ៊ុនព្រៃសម្បទាន

ក្នុងអាណត្តិទី ២ នៃ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ម៉ឺងម៉ាត់ និង ឈ្លាសវៃបំផុតរបស់សម្តេច នាយករដ្ឋមន្ត្រី **ហ៊ុន សែន** ដំណើរការនៃការកែទំរង់វិស័យព្រៃឈើបាននិងកំពុងទទួលនូវជោគជ័យជាបន្តបន្ទាប់ ជាពិសេសក្នុងការលុបបំបាត់អំពើអនាធិបតេយ្យព្រៃឈើគ្រប់ប្រភេទ ហើយបង្កើតបាននូវសណ្តាប់ធ្នាប់ និង ប្រក្រតីភាពជាមូលដ្ឋានលក្ខខណ្ឌគន្លឹះសំរាប់ឈានឆ្ពោះទៅរកការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព នៅកម្ពុជានាអនាគតឆាប់១ខាងមុខនេះ។ ទន្ទឹមនេះ ដំណើរការកែទម្រង់ការគ្រប់គ្រងព្រៃសម្បទានក៏បាននិងកំពុងអនុវត្តយ៉ាងសកម្មដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រោមជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ីបានដំណើរការ និង បញ្ចប់ការត្រួតពិនិត្យសើរើកិច្ចព្រមព្រៀងព្រៃសម្បទានកម្ពុជាទូទាំងប្រទេស ហើយជាលទ្ធផលគឺរាជរដ្ឋាភិបាលកម្ពុជាបានសំរេចលុបចោល និង ដកហូតព្រៃសម្បទានចំនួន ១៦ កន្លែង មានផ្ទៃដីសរុប ២.៤៣៧.៩៧០ ហិកតា ពី ១២ ក្រុមហ៊ុន។ រីឯក្រុមហ៊ុនព្រៃសម្បទានទាំង ១៧ ដែលនៅមានសុពលភាពបានឯកភាពធ្វើការសិក្សារៀបចំផែនការគ្រប់គ្រងព្រៃសម្បទានសារជាថ្មី និង ចរចាកិច្ចព្រមព្រៀងវិនិយោគទុនព្រៃសម្បទានសារជាថ្មីតាមគំរូបមាណីយ៍អន្តរជាតិនៃនិរន្តរភាពព្រៃឈើនៅត្រឹមដំណាច់ឆ្នាំ ២០០១ នេះ។ ប៉ុន្តែរហូតមកដល់បច្ចុប្បន្ននេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានពិនិត្យឃើញថាពុំទាន់មានក្រុមហ៊ុនព្រៃសម្បទានណាមួយ បានសំរេចលទ្ធផលទាំងស្រុងតាមកម្មវិធី ដែលបានឯកភាពគ្នាខាងលើនេះនៅឡើយ ។

អាស្រ័យហេតុនេះ ដើម្បីសំរេចឱ្យបាននូវគោលដៅជាចុងក្រោយក្នុងការបំពេញលក្ខខណ្ឌគន្លឹះសំរាប់ធានាដល់ការគ្រប់គ្រងព្រៃសម្បទានកម្ពុជាដោយនិរន្តរភាពនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ សំរេចធ្វើសេចក្តីប្រកាសជាសាធារណៈដូចខាងក្រោមនេះ :

១. ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០២ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ(នាយកដ្ឋានរុក្ខា-ប្រមាញ់) នឹងធ្វើការផ្អាកការផ្តល់លិខិតអនុញ្ញាតអោយធ្វើអាជីវកម្មព្រៃគុប ដល់ព្រៃសម្បទានិកទាំងអស់ រហូតដល់មានការយល់ព្រមលើផែនការគ្រប់គ្រងព្រៃឈើថ្មីច្បាស់លាស់ស្របទៅតាមតំរូវការនៃបទប្បញ្ញត្តិច្បាប់ និង បច្ចេកទេសសំរាប់ដំណើរការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ។

២. រាល់ព្រៃគុបដែលបាននិងកំពុងធ្វើអាជីវកម្មក្នុងឆ្នាំ ២០០១ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (នាយកដ្ឋានរុក្ខា-ប្រមាញ់)នឹងធ្វើការបិទព្រៃគុប ដោយបញ្ជាឱ្យព្រៃសម្បទានិកទាំងអស់ធ្វើការបញ្ឈប់រាល់សកម្មភាពអាជីវកម្មកាប់រំលំដើមឈើត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០១ នេះជាកំហិត រហូតដល់តំរូវការនៃបទប្បញ្ញត្តិច្បាប់ និង បច្ចេកទេសប្រតិបត្តិត្រូវបានបំពេញ ។

៣. នាយកដ្ឋានរុក្ខា-ប្រមាញ់ ត្រូវធ្វើសារពើភ័ណ្ឌឈើហ៊ុបស្របច្បាប់ ដែលបានមកពីការធ្វើអាជីវកម្មកាប់រំលំមុនថ្ងៃទី ០១ ខែមករា ឆ្នាំ២០០២ នៅក្នុងព្រៃគុប គំនរឈើ និង ទីកន្លែងផ្សេងៗទៀត ដែលស្ថិតនៅក្នុងតំបន់ព្រៃសម្បទាន ឬ ទីគំនរឈើផ្សេងៗទៀត ដើម្បីកំណត់ឱ្យបានច្បាស់លាស់នូវសន្និធិឈើហ៊ុបខាងលើសំរាប់រង់ចាំព្រៃសម្បទានិកបង់ថ្លៃសួយសារ និង ដឹកជញ្ជូនទៅកាន់កន្លែងកែច្នៃ ឬ ប្រើប្រាស់។ លទ្ធផលនៃសារពើភ័ណ្ឌឈើហ៊ុបទាំងអស់នេះ អាចនឹងផ្តល់ជូនតាមការស្នើសុំ។

៤. ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០០២ នាយកដ្ឋានរុក្ខា-ប្រមាញ់ ត្រូវផ្អាកការផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនឈើហ៊ុបដល់ព្រៃសម្បទានិក រហូតដល់មានការបង់ថ្លៃសួយសារ និង វាយត្រារួច។

៥. នាយកដ្ឋានរុក្ខា-ប្រមាញ់ ត្រូវរាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទនូវលទ្ធផលការងារ ដែលអនុវត្តបាន និង ការលំបាកក្នុងការអនុវត្តន៍ ដើម្បីក្រសួងមានវិធានការជាក់ស្តែង ។

សេចក្តីប្រកាសនេះ មានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី 13 ខែ ធ្នូ ឆ្នាំ ២០០១

រដ្ឋមន្ត្រី

ចិន្ត-ពារុន

**កន្លែងទទួល:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងពិតមាន
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ក្រសួងផែនការ
- ក្រសួងយុត្តិធម៌
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គ្រប់សាលាខេត្ត-ក្រុង

**"ដើម្បីជូនជ្រាប"**

- អង្គភាពក្រោមឱវាទក្រសួង
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទខេត្ត-ក្រុង
- សមាគមន៍ឧស្សាហកម្មឈើកម្ពុជា
- គ្រប់ក្រុមហ៊ុនព្រៃសម្បទាន

**"ដើម្បីអនុវត្ត"**